ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**
លេខៈ ០៧ ដនស..រសជ.សណន

ភ្នំពេញ, ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ជំរាបមក

### លោកស្រី-អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត

**កម្មវត្ថុ** : ការណែនាំស្តីពីការចុះបញ្ជីអំពីការរឹបអូសដី-ផ្ទះតាមអំណាចដីកាសំរេចចាប់ផ្តើមអនុវត្តរបស់តុលាការ ។

**យោង** : - លិខិតលេខ ១៧៧៦រ.៩៦៧.០៨ ចុះថ្ងៃទី ១១/១២/០៨ របស់សាលាដំបូងក្រុងភ្នំពេញ

- ចំណារឯកភាពរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៩

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកស្រី-អស់លោកប្រធានមន្ទីរឱ្យបានជ្រាបថា:ករណីការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដែលក្រមនីតិវិធីរដ្ឋប្បវេណីបានតម្រូវ បច្ចុប្បន្នក្រុមការងារអន្តរក្រសួង រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងពិភាក្សាដើម្បីកំណត់ទំរង់បែបបទ និងរូបមន្តក្នុងការធ្វើលេខាចារឹក ប៉ុន្តែពុំទាន់បានសម្រេចជាលទ្ធផលនៅឡើយ ។ ចំពោះមុខ ដោយមានភាពចាំបាច់ ហើយដើម្បីកុំឱ្យរាំងស្ទះដល់នីតិវិធីរបស់តុលាការ ក្រសួងសូមធ្វើការណែនាំអោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានី-ខេត្ត អនុវត្តតាមរូបមន្តដូចខាងក្រោម :

" ត្រូវបានរឹបអូសតាមដីកាសំរេចចាប់ផ្តើមអនុវត្តលេខ..............ចុះថ្ងៃ........... របស់តុលាការអនុវត្ត ..........ល.រ **AJ**........" ត្រូវសរសេរដោយដៃត្រង់ខ្ទង់បន្ទុកលើអចលនវត្ថុ ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដីធ្លី ។

អាស្រ័យហេតុនេះ សូមលោកស្រី-អស់លោកប្រធានមន្ទីរជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើ តាមការគួរ ។

សូមលោកស្រី-អស់លោកប្រធានមន្ទីរទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។៚

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ចម្លងជូន :**

- ក្រសួងយុត្តិធម៌
- អគ្គនាយកដ្ឋាន សុរិយោដី និងភូមិសាស្ត្រ
- គ្រប់មន្ទីរ ដ.ន.ស.ស រាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

**អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ**

**Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @Camnet. Com. Kh**